ភ្នំពេញ , ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ១៩៩៣

**សារាចរ លេខ ០១ សរ**

## សហប្រធានរដ្ឋាភិបាលជាតិបណ្ដោះអាសន្ន កម្ពុជា

**សូមជំរាបមក**

## អស់លោក អភិបាល ខេត្ត ក្រុង ទូទាំងប្រទេសកម្ពុជា

**កម្មវត្ថុ :** អំពីកម្មសិទ្ធិស្របច្បាប់ របស់ប្រជាពលរដ្ឋបច្ចុប្បន្ន និង កម្មសិទ្ធិសាធារណៈ ។

យោងសេចក្ដីប្រកាសរបស់រដ្ឋាភិបាលជាតិបណ្ដោះអាសន្នកម្ពុជា ចុះថ្ងៃទី ០២ខែ កក្កដា ឆ្នាំ១៩៩៣ និង ដោយពិនិត្យឃើញ នៅតាមខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ជាច្រើនកើតឡើងនូវអំពើឃោរឃៅក្នុងការដណ្ដើមកាន់កាប់ដីធ្លី ផ្ទះសម្បែង អាគារ ទីធ្លា និងសួនសាធារណៈបណ្ដាលអោយប្រជារាស្ត្រមានការភ័យព្រួយដល់កម្មសិទ្ធិរបស់ខ្លួនដែលចាំបាច់ត្រូវមានការជួយដោះស្រាយជាបន្ទាន់ ។

រដ្ឋាភិបាលជាតិបណ្ដោះអាសន្នកម្ពុជា សូមអោយអភិបាលខេត្ត ក្រុង ទូទាំងប្រទេស ចាត់វិធានការជាបន្ទាន់ ដើម្បីធានាការពារ កម្មសិទ្ធិស្របច្បាប់ បច្ចុប្បន្នរបស់ប្រជាពលរដ្ឋ ដូច ជាដីធ្លី ផ្ទះសម្បែង និង ទ្រព្យសម្បត្តិរបស់រដ្ឋ ដូចជាអាគារសាធារណៈ ទីធ្លា និង សួន សាធារណៈ ហើយបញ្ជូនជនល្មើសទៅតុលាការ ដើម្បីផ្ដន្ទាទោសតាមច្បាប់ជាធរមាន ។

ក្រោយបានទទួលសារាចរនេះ អភិបាលខេត្ត ក្រុង ទាំងអស់ត្រូវរាយការណ៍ជាលាយលក្ខអក្សរមកក្រសួងមហាផ្ទៃក្នុងរយៈពេល ១ ខែ បានន័យថានៅដំណាច់ខែ កក្កដា ឆ្នាំ ១៩៩៣ អំពីលទ្ធផលដែលសំរេចបានក្នុងបញ្ហាទាំងអស់ខាងលើនេះ ។

**សហប្រធាន**

**រដ្ឋាភិបាលជាតិបណ្ដោះអាសន្នកម្ពុជា**

ព្រះហស្តលេខា ហត្ថលេខា

ស្ដេចក្រុមហ្លួង **នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

* * *